# ឯកសារណែនាំ
# ស្តីពី
# កិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល

## ១- សាវតា

នាព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ នៅវិមានសន្តិភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិមួយចំនួនពិភាក្សាអំពីកិច្ចប្រតិបត្តិការនានាសម្រាប់ឆ្លើយតបនឹងគ្រោះទឹកជំនន់ឆ្នាំ២០១១ និងកិច្ចប្រឹងប្រែងក្រោយទឹកជំនន់ក្នុងឆ្នាំ២០១២ ។ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានលើកឡើងអំពីមេរៀននិងបទពិសោធន៍ជាច្រើន ដែលក្នុងនោះរួមមានបញ្ហាសម្របសម្រួល ការចែករំលែកព័ត៌មាន ការរៀបចំយន្តការគាំទ្រ និងការផ្តល់សេវាជាដើម ។

ក្នុងជំនួបនាពេលនោះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានបញ្ជាក់សារជាថ្មីអំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការបន្តធ្វើការងារក្នុងភាពជាដៃគូជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ជាផលប្រយោជន៍ដល់ការអភិវឌ្ឍន៍ប្រទេស ។ ក្នុងស្មារតីនេះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានសម្រេចឱ្យរៀបចំកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំរវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមាន*សកម្មភាពប្រតិបត្តិការច្បាស់លាស់* សម្រាប់ពិភាក្សា «*វិស័យឬប្រធានបទជាក់លាក់*» ដើម្បីធានាថា រាល់ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលមានសង្គតិភាពជាមួយនឹងអាទិភាពអភិវឌ្ឍន៍របស់ប្រទេស ហើយបានសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ទាំងខាងសកម្មភាព ទាំងខាងធនធាន ។ កិច្ចពិគ្រោះយោបល់នឹងផ្តល់កាលានុវត្តភាពសម្រាប់ពិភាក្សាស៊ីជម្រៅ ក្នុងន័យស្ថាបនា ដើម្បីពង្រឹងការយល់ដឹងឯកភាពគ្នាអំពីបណ្តាបញ្ហាប្រឈមនិងដំណោះស្រាយ សម្រាប់បង្កើនគុណភាពនៃការផ្តល់សេវា ស្របតាមទស្សនៈវិស័យនៃកិច្ចអភិវឌ្ឍន៍ជាតិ ។ ឯកសារណែនាំនេះបានលើកឡើងនូវការងារមួយចំនួនដែលពាក់ព័ន្ធនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃកិច្ចពិគ្រោះយោបល់ ដើម្បីធានាអត្ថប្រយោជន៍ខ្ពស់ ។

## ២- គោលបំណងនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ

គោលបំណងនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំគឺការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់វិស័យ និងរបស់ថ្នាក់ក្រោមជាតិ ។ ក្នុងស្មារតីនេះ កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនឹងៈ

ក- ផ្តោតលើ «*វិស័យ ឬ ប្រធានបទជាក់លាក់*» ដើម្បីកំណត់គោលដៅរួមគ្នា និងសកម្មភាពជាក់ស្តែងរបស់រាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល ហើយក្នុងករណីចាំបាច់ កំណត់សកម្មភាពរួមគ្នាដើម្បីលើកកំពស់គុណភាពនៃកិច្ចប្រតិបត្តិការឱ្យកាន់តែប្រសើរឡើង និងបង្កើនប្រសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ ។

ខ- បង្កើនការយល់ដឹងឯកភាពគ្នានិងការចែករំលែកព័ត៌មានស្តីពីវឌ្ឍនភាព បញ្ហាប្រឈមនិងដំណោះស្រាយ ។ ការចែករំលែកព័ត៌មានគួរយកចិត្តទុកដាក់ដល់ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានក្នុងវិស័យគន្លឹះៗ ក៏ដូចជាព័ត៌មានដែលពាក់ព័ន្ធនឹងសកម្មភាពមនុស្សធម៌ផងដែរ ។

គ- ចែករំលែកបទពិសោធន៍ និងការអនុវត្តគំនិតផ្តួចផ្តើមថ្មីៗតាមរយៈការរៀនសូត្រ និងដកស្រង់បទពិសោធន៍ការងារសម្រាប់បង្កើនការយល់ដឹង និងការផ្លាស់ប្តូរព័ត៌មានក្នុងមជ្ឈដ្ឋានអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជារវាងរាជរដ្ឋាភិបាលនិងអង្គការទាំងនេះ ដែលកិច្ចការទាំងអស់នេះមានសារៈសំខាន់សម្រាប់ការរៀបចំនិងការសម្រេចចិត្តខាងគោលនយោបាយ និងការអនុវត្តកម្មវិធី ។

ឃ- បង្កើតនិងពង្រឹងទំនាក់ទំនង តាមរយៈការផ្សាភ្ជាប់កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនេះជាមួយនឹងយន្តការពិភាក្សាដែលមានស្រាប់នៅកម្រិតជាតិ កម្រិតវិស័យ និងថ្នាក់ក្រោមជាតិ ព្រោះថាបញ្ហាទាំងឡាយដែលបានលើកនៅក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនេះ អាចលើកយកមកពិភាក្សាលម្អិតបន្ថែមទៀត និងស្វែងរកដំណោះស្រាយ ព្រមទាំងសម្រាប់តាមដានវឌ្ឍនភាពតាមរយៈយន្តការទាំងនេះ ។

## ៣- គោលការណ៍ណែនាំសម្រាប់ការរៀបចំកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ

គោលការណ៍មួយចំនួនដូចខាងក្រោមនឹងផ្តល់សារៈប្រយោជន៍សម្រាប់ធានាថា គ្រប់ភាគីទាំងអស់បានយល់ច្បាស់អំពីបរិបទនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំរវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល ។

កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំមានគោលដៅពង្រឹងភាពជាដៃគូ តាមរយៈការអនុវត្តគោលការណ៍សំខាន់ៗដូចខាងក្រោម៖

ក- *ស្មារតីស្ថាបនា៖* កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំត្រូវបានរៀបចំឡើង ដើម្បីជម្រុញការអនុវត្តឱ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ជាតិ ។ ក្នុងស្មារតីនេះ កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនឹងផ្តល់កាលានុវត្តភាពសម្រាប់បញ្ចេញមតិយោបល់ ដោយផ្អែកលើបទពិសោធន៍ថ្មីៗដែលទទួលបាន ដើម្បីបង្កើនប្រសិទ្ធភាពតាមរយៈការកែលំអគោលនយោបាយអភិវឌ្ឍន៍ និងរបៀបអនុវត្តបណ្តាគម្រោងនិងកម្មវិធី ព្រមទាំងការប្រើប្រាស់ធនធានហិរញ្ញវត្ថុនិងមុខជំនាញឱ្យកាន់តែប្រសើរឡើង ។

ខ- *ការសម្របសម្រួល៖* កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំគឺជាកាលានុវត្តភាពសម្រាប់ប្រតិបត្តិករនិងដៃគូទាំងអស់បានពិភាក្សា ដើម្បីធានាថាគ្រប់មុខងារសំខាន់ៗទាំងអស់ (រួមទាំងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មាននិងការចែករំលែកព័ត៌មាន) ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយកិច្ចប្រតិបត្តិការជាន់គ្នា ។

គ- *ការពិគ្រោះយោបល់៖* កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនឹងបង្កើនទំនាក់ទំនងទ្វេទិស ប្រកបដោយប្រសិទ្ធភាព ព្រោះភាគីទាំងអស់អាចស្វែងយល់ និងស្រាយបំភ្លឺលើបណ្តាបញ្ហាដែលជះឥទ្ធិពលដល់ការអនុវត្តន៍កម្មវិធី និងការងាររបស់ពួកគេ ។

ឃ- *ការបំពេញបន្ថែម៖* កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនឹងជួយបង្កើនប្រសិទ្ធភាពការងារ តាមរយៈការពង្រឹងកិច្ចប្រតិបត្តិការរវាងបណ្តាផ្នែកនានា និងតាមរយៈការធានាសង្គតិភាពរវាងបណ្តាគោលនយោបាយ និងរវាងបណ្តាវិស័យ ។

ង- *កិច្ចសហការ ៖* កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំគឺជាកាលានុវត្តភាព (តាមរយៈការរៀនសូត្រពីបទពិសោធន៍បច្ចុប្បន្ន) ដើម្បីពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់សេវាជាទូទៅ ឬការផ្តល់សេវាតាមកិច្ចសន្យាក្នុងវិស័យគន្លឹះមួយចំនួន ក៏ដូចជាការសម្របសម្រួលការងារសម្រាប់ការជួយសង្គ្រោះបន្ទាន់ ។

ច) *អត្ថប្រយោជន៍ទ្វេទិស៖* គ្រប់ភាគីទាំងអស់នឹងប្រើប្រាស់លទ្ធផលនៃកិច្ចពិគ្រោះយោបល់នេះ សម្រាប់តម្រង់ទិសការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងសម្រេចបានលទ្ធផលសម្រាប់ជាគុណប្រយោជន៍ដល់ប្រជាជនកម្ពុជា ។ លទ្ធផលនេះអាចសម្រេចទៅបាន តាមរយៈការបង្កើនការយល់ដឹងអំពីការងាររបស់ប្រតិបត្តិករដទៃទៀតនៅក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ ។

## ៤- ការរៀបចំកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ - តួនាទីនិងការទទួលខុសត្រូវ

កិច្ចពិគ្រោះយោបល់នឹងដំណើរការរយៈពេលកន្លះថ្ងៃ ហើយផ្តោតលើ *«វិស័យ ឬ ប្រធានបទមួយជាក់លាក់»* ដូចជាវិស័យអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទជាដើម ។ វិស័យឬប្រធានបទត្រូវកំណត់ជាមុនដោយ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដោយផ្អែកលើសារៈសំខាន់របស់វិស័យឬប្រធានបទនោះនៅក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។



8

ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ តួនាទីនិងភារៈទទួលខុសត្រូវបានកំណត់ដូចខាងក្រោម៖

ក- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសម្របសម្រួលកិច្ចការទូទៅរបស់កិច្ចពិគ្រោះយោបល់ ។

ខ- លេខាធិការដ្ឋាននៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ៖ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) ក្រោមការគ្រប់គ្រងរបស់ឯកឧត្តម **ឈឿង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋានសម្រាប់កិច្ចពិគ្រោះយោបល់នេះ ។ តាមការចង្អុលណែនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** លេខាធិការដ្ឋានត្រូវសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់សមាសភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចពិគ្រោះយោបល់ និងសម្របសម្រួលជាមួយក្រសួងនិងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចពិគ្រោះយោបល់ ។ លេខាធិការដ្ឋានទទួលខុសត្រូវក្នុងការធ្វើសុពលភាពអំពីសកម្មភាពនិងធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលកំពុងប្រតិបត្តិការនៅក្នុងវិស័យនិមួយៗ ហើយក៏ទទួលខុសត្រូវអំពីប្រព័ន្ធគាំទ្រសម្រាប់កិច្ចពិគ្រោះយោបល់ផងដែរ ។ ទន្ទឹមនឹងនេះ ក៏មានកាតព្វកិច្ចរៀបចំកិច្ចប្រជុំត្រៀមជាមួយបណ្តាក្រសួងនិងស្ថាប័ននិងអង្គការពាក់ព័ន្ធ ហើយបន្ទាប់មក ត្រូវរៀបចំជំនួយស្មារតីជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជ្រាបដ៏ខ្ពង់ខ្ពស់ និងសូមអនុសាសន៍ណែនាំជាយថាហេតុ ។ លើសពីនេះ លេខាធិការដ្ឋានត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចពិគ្រោះយោបល់ ដោយរំលេចពីបណ្តាសកម្មភាពដែលបានឯកភាពសម្រាប់អនុវត្តបន្ត ។

គ- ក្រសួងឬស្ថាប័ននាំមុខរបស់រាជរដ្ឋាភិបាល ត្រូវសហការជាមួយលេខាធិការដ្ឋានសម្រាប់រៀបចំសមាសភាពអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវអញ្ជើញចូលរួម និងរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ។ ទន្ទឹមនឹងនេះ នៅមុនពេលកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ក៏ត្រូវរៀបចំកិច្ចប្រជុំត្រៀមជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកំណត់ និងដោះស្រាយបញ្ហាឱ្យបានច្រើនជាអតិប្បរមា ដើម្បីឱ្យកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំអាចផ្តោតលើបញ្ហាណាដែលត្រូវស្នើសុំការណែនាំ ឬការសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ឬលើបញ្ហាណាដែលតម្រូវឱ្យមានធាតុចូល និងការពិភាក្សាពីក្រសួងពាក់ព័ន្ធដទៃទៀត ។ លើសពីនេះ ក៏ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការតាមដានវឌ្ឍនភាពនៃការអនុវត្តរាល់ការសម្រេចរបស់កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ហើយត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព៦ខែបន្ទាប់ពីកិច្ចប្រជុំ ជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដើម្បីជ្រាបជាព័ត៌មានដ៏ខ្ពង់ខ្ពស់ និងបន្តធ្វើបច្ចុប្បន្នភាពសម្រាប់បញ្ចូលក្នុងសុន្ទរកថាគន្លឹះរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សម្រាប់កិច្ចពិគ្រោះយោបល់លើកក្រោយៗទៀត ។

ឃ- ក្រុមសម្របសម្រួលរបស់អង្គការមិនមែនរដ្ឋាភិបាល (អាចជារចនាសម្ព័ន្ធសម្របសម្រួលមានស្រាប់របស់អង្គការមិនមែនរដ្ឋាភិបាល ឬក៏ជាក្រុមការងារដែលបង្កើតឡើងសម្រាប់តែកិច្ចប្រជុំប្រចាំឆ្នាំនេះ) គឺជា*«ភ្នាក់ងារតំណាងសំខាន់របស់អង្គការមិនមែនរដ្ឋាភិបាល»* សម្រាប់ទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល ។ ភ្នាក់ងារតំណាងនេះត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលកិច្ចប្រជុំត្រៀមនានារបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីកំណត់បណ្តាបញ្ហាដែលកំពុងប្រឈមក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។ ភ្នាក់ងារតំណាងនេះក៏ត្រូវបានអញ្ជើញប្រជុំសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈ ហើយក៏ជាតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងរយៈពេលកន្លះថ្ងៃនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំផងដែរ ។ លើសពីនេះ ក៏ត្រូវមានកាតព្វកិច្ចសម្របសម្រួល និងតាមដានវឌ្ឍនភាពនៃការអនុវត្តន៍សកម្មភាពដែលបានឯកភាពក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ហើយដែលស្ថិតនៅក្នុងដែនទទួលខុសត្រូវរបស់អង្គការមិនមែនរដ្ឋាភិបាល ។ អង្គការមិនមែនរដ្ឋាភិបាលអាចផ្តួចផ្តើមគំនិតឱ្យមានកិច្ចប្រជុំរបស់ខ្លួន សម្រាប់រៀនសូត្រនិងដកស្រង់បទពិសោធន៍ ក៏ដូចជាសម្រាប់តាមដានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពដែលបានឯកភាពក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំផងដែរ ។

ភ្នាក់ងារតំណាងសំខាន់ត្រូវជ្រើសរើសដោយអង្គការមិនមែនរដ្ឋាភិបាលខ្លួនឯង ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមៈ

ក- កិច្ចប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធត្រង់ជាមួយនឹងវិស័យ ឬប្រធានបទនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ។

ខ- មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំកិច្ចពិភាក្សាផ្ទៃក្នុងរបស់ខ្លួន និងសម្រួលក្នុងការចែករំលែកព័ត៌មានស្តីពីសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យ ឬប្រធានបទនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ហើយក៏មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញតួនាទីជាអ្នកសម្របសម្រួលសម្រាប់ត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ដំណើរការនៃការពិភាក្សា និងតាមដានការអនុវត្ត ។

គ- មានសុឆន្ទៈចូលរួម និងសម្របសម្រួលការពិភាក្សាក្នុងភាពជាដៃគូនិងក្នុងស្មារតីស្ថាបនា រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ផ្តល់កិច្ចសម្របសម្រួលសម្រាប់ការតាមដានវឌ្ឍនភាព រួមទាំងរៀបចំរបាយការណ៍៦ខែ បន្ទាប់ពីកិច្ចពិគ្រោះយោបល់ ជូនក្រសួងឬស្ថាប័ននាំមុខរបស់រាជរដ្ឋាភិបាល ។

រីឯការរៀបចំកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនឹងអនុវត្តតាមជំហានដូចខាងក្រោមៈ

ក- **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សម្រេចលើវិស័យឬប្រធានបទ និងកំណត់កាលបរិច្ឆេទនៃជំនួប តាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ។

ខ- គ.ជ.នា/ក.អ.ក ត្រូវប្រើប្រាស់ប្រព័ន្ធទិន្នន័យអង្គការមិនមែនរដ្ឋាភិបាល និងពិភាក្សាជាមួយក្រសួងនិងស្ថាប័ន ក្រុមការងារបច្ចេកទេសចម្រុះ និងក្រុមសម្របសម្រួលរបស់អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញការងារនៅថ្នាក់ក្រោមជាតិ ដើម្បីកំណត់ឈ្មោះបណ្តាអង្គការមិនមែនរដ្ឋាភិបាលដែលកិច្ចប្រតិបត្តិការរបស់ខ្លួនមានការពាក់ព័ន្ធត្រង់ជាមួយនឹងវិស័យឬប្រធានបទនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ។

គ- អង្គការមិនមែនរដ្ឋាភិបាលត្រូវប្រើប្រាស់រចនាសម្ព័ន្ធសម្របសម្រួលមានស្រាប់របស់ខ្លួន ឬក៏ជាក្រុមការងារដែលបង្កើតឡើងសម្រាប់តែកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនេះ ដើម្បីជ្រើសរើសក្រុមសម្របសម្រួលរបស់ខ្លួន តាមលក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ខាងលើ និងត្រូវរៀបចំប្រជុំត្រៀមឬពិភាក្សាផ្ទៃក្នុង ដើម្បីកំណត់បណ្តាបញ្ហាដែលចង់លើកពិភាក្សាក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ។

ឃ- បន្ទាប់មក ភ្នាក់ងារសំខាន់របស់អង្គការមិនមែនរដ្ឋាភិបាលនឹងជួបជាមួយ គ.ជ.នា/ក.អ.ក និងក្រសួងនិងស្ថាប័ននាំមុខ ដើម្បីជម្រាបអំពីការត្រៀមរៀបចំរបស់ខ្លួន ពិសេសអំពីបណ្តាបញ្ហាដែលអង្គការមិនមែនរដ្ឋាភិបាលស្នើសុំពិភាក្សាក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ។

ង- ប្រសិនបើចាំបាច់ លេខាធិការដ្ឋាននិងក្រសួងនិងស្ថាប័ននាំមុខ អាចប្រជុំពិភាក្សាជាមួយគ្នា ដើម្បីឯកភាពលើបណ្តាបញ្ហាដែលស្នើសុំការពិភាក្សាក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ។

ច- គ.ជ.នា/ក.អ.ក ដោយសហការជាមួយក្រសួងនិងស្ថាប័ននាំមុខ រៀបចំសេចក្តីព្រាងបញ្ចប់របៀបវារៈ និងបណ្តាបញ្ហាដែលអង្គការមិនមែនរដ្ឋាភិបាលបានស្នើសុំពិភាក្សា ជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ដើម្បីរាយការណ៍ជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ ។

កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំដែលមានរយៈពេលកន្លះថ្ងៃនេះ ត្រូវដំណើរការតាមរបៀបវារៈដូចខាងក្រោមៈ

ក- សុន្ទរកថាស្វាគមន៍និងការបង្ហាញរបៀបវារៈ ដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ដើម្បីជម្រាបពីទិដ្ឋភាពទូទៅនៃវឌ្ឍនភាពរបស់វិស័យ សមិទ្ធផល បញ្ហាប្រឈម និងទិសដៅអនាគត

ខ- សុន្ទរកថារបស់ក្រុមសម្របសម្រួលរបស់អង្គការមិនមែនរដ្ឋាភិបាល

គ- សុន្ទរកថាគន្លឹះរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**

ឃ- បទបង្ហាញរបស់តំណាងអង្គការមិនមែនរដ្ឋាភិបាល លើសមិទ្ធផល បញ្ហាប្រឈម និងបណ្តាបញ្ហាសម្រាប់ពិភាក្សា និងលើកសំណើអំពីសកម្មភាពរបស់ខ្លួន សម្រាប់អនុវត្តនាពេលអនាគត

ង- ការស្រាយបំភ្លឺរបស់ក្រសួង/ ស្ថាប័នពាក់ព័ន្ធ រួមទាំងសកម្មភាពសម្រាប់អនុវត្តនាពេលអនាគត និងប្រព័ន្ធសម្រាប់តាមដានក្រោយជំនួបប្រចាំឆ្នាំ

ច- ការពិភាក្សាពេញអង្គ

ឆ- ការឯកភាពលើសកម្មភាព និងប្រព័ន្ធតាមដាន

ជ- មតិបូកសរុប និងសុន្ទរកថាបិទរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ។

ចំពោះការតាមដានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពនានាដែលបានឯកភាពក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ក្រសួងនិងស្ថាប័ននាំមុខមានភារកិច្ចតាមដានលើបណ្តាសកម្មភាពណាដែលឋិតក្នុងដែនសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ រីឯភ្នាក់ងារតំណាងសំខាន់របស់អង្គការមិនមែនរដ្ឋាភិបាលមានភារកិច្ចរៀបចំរបាយការណ៍សង្ខេបស្តីពីសកម្មភាពដែលបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល បន្ទាប់ពីកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ។ ក្រសួងនិងស្ថាប័ននាំមុខក៏ត្រូវបូកសរុបរបាយការណ៍ ៦ ខែ បន្ទាប់ពីកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ ជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ។ របាយការណ៍បូកសរុបនេះក៏អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ពិភាក្សាបន្ត និងសម្របសម្រួលការងាររវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលផងដែរ ។

## ៥- សមាសភាពចូលរួម និងកាលបរិច្ឆេទនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ

*សមាសភាពចូលរួម* គឺអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិទាំងឡាយដែលកំពុងចូលរួមយ៉ាងសកម្មក្នុងវិស័យឬក្នុងប្រធានបទនៃកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ រួមមាន៖

ក- បណ្តាអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងប្រតិបត្តិការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

ខ- អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលបានផ្តល់ហិរញ្ញប្បទានដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

គ- ដៃគូអភិវឌ្ឍន៍ដែលបានផ្តល់ហិរញ្ញប្បទានដល់អង្គការមិនមែនរដ្ឋាភិបាល ។

ទន្ទឹមនឹងនេះ បណ្តាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យនិងប្រធានបទនៃកិច្ចប្រជុំប្រចាំឆ្នាំក៏ត្រូវអញ្ជើញចូលរួមក្នុងកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនេះ។ លិខិតអញ្ជើញត្រូវរៀបចំដោយលេខាធិការដ្ឋាន ។

*កាលបរិច្ឆេទ៖* កិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំនឹងរៀបចំក្នុងត្រីមាសទី១នៃឆ្នាំ ឬតាមពេលវេលាសមស្របរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សម្រាប់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេច និងដើម្បីតម្រង់និងសម្រួចសកម្មភាពអនុវត្ត ។

---



8